# ជំនួយស្មារតី
## ពិធីផ្សព្វផ្សាយសារាចរណែនាំ
## ស្ដីពី
## វិធានការចាំបាច់នានាក្នុងការពង្រឹងការគ្រប់គ្រងធនធានធម្មជាតិ

ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៦

- ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន
- ឯកឧត្តមនាយឧត្តមសេនីយ៍ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ
- ឯកឧត្តមនាយឧត្តមសេនីយ៍ អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ
- ឯកឧត្តមនាយឧត្តមសេនីយ៍ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស
- ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាប្រធានរដ្ឋបាលព្រៃឈើ
- ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល
- ឯកឧត្តមប្រធានក្រុមប្រឹក្សា និងឯកឧត្តមអភិបាលរាជធានី ខេត្ត
- ឯកឧត្តម លោកជំទាវ លោក លោកស្រីតំណាងក្រសួង ស្ថាប័ននានានៃរាជរដ្ឋាភិបាលកម្ពុជា
- លោក លោកស្រីតំណាងសហគមន៍មូលដ្ឋាន អង្គការសង្គមស៊ីវិលពាក់ព័ន្ធនានា

## I. សេចក្ដីផ្ដើម

- ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក !
- ផ្អែកតាមមតិដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចតេជោនាយករដ្ឋមន្ត្រី** ថ្ងៃនេះក្នុងនាមក្រសួងមហាផ្ទៃ និងក្នុងនាម **គ.ជ.អ.ប** និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ដែលបានអញ្ជើញមកចូលរួម**ពិធីផ្សព្វផ្សាយ**នាព្រឹកនេះ។
- គោលបំណងសំខាន់នៃពិធីនាព្រឹកនេះ គឺការផ្សព្វផ្សាយខ្លឹមសារនៃ**សារាចរណែនាំស្ដីពីវិធានការចាំបាច់នានាក្នុងការពង្រឹងការគ្រប់គ្រងធនធានធម្មជាតិ** ដែលបានដាក់ចេញដោយរាជរដ្ឋាភិបាល នាថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៦កន្លងទៅថ្មីៗនេះ ជូនដល់ថ្នាក់ដឹកនាំក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ មន្ត្រីមានសមត្ថកិច្ច តំណាងសហគមន៍មូលដ្ឋាន និងអង្គការ

សង្គមស៊ីវិលពាក់ព័ន្ធនានាឱ្យបានយល់ជ្រួតជ្រាប សំដៅលើកកម្ពស់កិច្ចសហការគ្នាឱ្យបានកាន់តែជិតស្និទ្ធ និងចូលរួមយ៉ាងសកម្មក្នុងការចាត់វិធានការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិឱ្យមានប្រសិទ្ធភាពខ្ពស់។

- ឆ្លៀតក្នុងឱកាសនេះ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមសំដែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធទាំងអស់ដែលបានធ្វើការប្ដេជ្ញាចិត្តរួមគ្នាក្នុងការរក្សាការពារធនធានព្រៃឈើ សត្វព្រៃ ធនធានជលផល និងធនធានធម្មជាតិក្នុងរយៈពេលកន្លងមក ក៏ដូចបច្ចុប្បន្ន។

  អាស្រ័យដោយឆន្ទៈ និងការប្ដេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល និងដោយមានការចូលរួមយ៉ាងសកម្មពីគ្រប់ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធនានា ទើបធ្វើឲ្យប្រទេសយើងនៅសេសសល់ធនធានធម្មជាតិនានាប្រកបដោយសក្ដានុពលដែលត្រូវរួមគ្នាបន្តរក្សាការពារឲ្យបានស្ថិតស្ថេរគង់វង្សសម្រាប់ជាមរតកដ៏មានតម្លៃរបស់ជាតិ និងសម្រាប់កូនចៅជំនាន់ក្រោយៗទៀត។

## II. បញ្ហាប្រឈម និងទស្សនៈវិស័យក្នុងការកែទម្រង់ការគ្រប់គ្រងធនធានធម្មជាតិ

### ១. បញ្ហាប្រឈម

- ទោះបីយ៉ាងនេះក្តី ក៏ធនធានធម្មជាតិដែលនៅសេសសល់ទាំងនេះកំពុងទទួលរងសម្ពាធពីការបំផ្លិចបំផ្លាញតាមគ្រប់រូបភាព។

### ២. ទស្សនៈវិស័យ

- ផ្ដើមចេញពីបញ្ហាប្រឈមនេះ ទាមទារឲ្យយើងសិក្សា ពិនិត្យឡើងវិញទាំងក្របខ័ណ្ឌគោលនយោបាយ ក្របខ័ណ្ឌច្បាប់ រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងវិធានការនានាដែលបានអនុវត្តកន្លងមក សំដៅដាក់ចេញនូវក្របខ័ណ្ឌគោលនយោបាយ ក្របខ័ណ្ឌច្បាប់ ប្រព័ន្ធ រចនាសម្ព័ន្ធគ្រប់គ្រង និងវិធានការដែលមានលក្ខណៈសមស្របឆ្លើយតបតាមការវិវត្តន៍ប្រែប្រួលរបស់សង្គម សេដ្ឋកិច្ច និងគោលនយោបាយកំណែទម្រង់នានារបស់រាជរដ្ឋាភិបាល។

### ៣. ដំណើរការកំណែទម្រង់

- រាជរដ្ឋាភិបាលបាន និងកំពុងផ្ដោតការយកចិត្តទុក ដាក់យ៉ាងខ្លាំងក្នុងការធ្វើកំណែទម្រង់លើ

ការគ្រប់គ្រងធនធានធម្មជាតិ ជាពិសេសលើការគ្រប់គ្រងព្រៃឈើ ជលផល និងតំបន់ការពារធម្មជាតិ ដោយបាន និងកំពុងធ្វើវិសោធនកម្ម ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល និងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។

- ជារួម ច្បាប់ទាំង៣នេះបានរៀបចំឡើងក្នុងពេលដែលប្រទេសយើងអនុវត្តប្រព័ន្ធគ្រប់គ្រងបែបមជ្ឈការ ដោយបានផ្តល់សិទ្ធិផ្តាច់មុខទៅឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថានក្នុងការគ្រប់គ្រង អភិវឌ្ឍ និងអភិរក្សព្រៃឈើ ជលផល និងតំបន់ការពារធម្មជាតិ តាមរយៈអង្គភាពខ្សែបណ្តោយរបស់ខ្លួន រួមមានដូចជា រដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល និងរដ្ឋបាលការពារ និងអភិរក្សធម្មជាតិជាដើម។ ប្រព័ន្ធគ្រប់គ្រង និងរចនាសម្ព័ន្ធគ្រប់គ្រងតាមច្បាប់ទាំងនេះ មានលក្ខណៈសមស្របសម្រាប់តែកាលៈទេសៈនោះតែប៉ុណ្ណោះ។
- ប៉ុន្តែស្របពេលដែលយើងកំពុងធ្វើការកែទម្រង់ការគ្រប់គ្រងរដ្ឋបាលតាមប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ ទាមទារត្រូវពិនិត្យមើលឡើងវិញ និងកែលម្អច្បាប់ លិខិតបទដ្ឋាននានា រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងតាមវិស័យនានាក្នុងនោះរួមទាំងការគ្រប់គ្រងព្រៃឈើ ជលផល តំបន់ការពារធម្មជាតិ ឲ្យសមស្របជាមួយកំណែទម្រង់ការគ្រប់គ្រងរដ្ឋបាល។
- ជាក់ស្តែងច្បាប់បច្ចុប្បន្ន ពុំបានផ្តល់សិទ្ធិអំណាច និងការទទួលខុសត្រូវច្បាស់លាស់ទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងអាជ្ញាធរមានសមត្ថកិច្ចផ្សេងៗទៀតឡើយ គឺបានផ្តល់តួនាទីត្រឹមតែការផ្តល់នូវកិច្ចសហការ ទៅតាមការស្នើសុំរបស់រដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល និងរដ្ឋបាលតំបន់ការពារ និងអភិរក្សធម្មជាតិតែប៉ុណ្ណោះ។
- ការពុំបានផ្តល់សិទ្ធិអំណាច តួនាទី និងការទទួលខុសត្រូវច្បាស់លាស់ឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងៗទៀតបានធ្វើឱ្យការចាត់វិធានការបង្ការទប់ស្កាត់បទល្មើសព្រៃឈើ ជលផល និងការបំផ្លាញតំបន់ការពារធម្មជាតិ ក៏ដូចជាការអភិវឌ្ឍ និងអភិរក្សធនធានធម្មជាតិពុំសូវមានប្រសិទ្ធភាព ហើយជាទូទៅ តែងតែឆ្លើយដាក់គ្នាទៅវិញទៅមករវាងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល រដ្ឋបាលការពារនិងអភិរក្សធម្មជាតិ រដ្ឋបាល ថ្នាក់ក្រោមជាតិ និងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត។
- អាស្រ័យហេតុនេះ ដើម្បីធានាដល់ការពង្រឹងការគ្រប់គ្រង ការអភិវឌ្ឍ និងការអភិរក្សធនធានធម្មជាតិប្រកបដោយនិរន្តរភាព ទាមទារឱ្យមានការធ្វើវិសោធនកម្មច្បាប់ទាំង៣នេះ និងកែសម្រួលលិខិតបទដ្ឋានពាក់ព័ន្ធនានាផ្សេងទៀត ដើម្បីបែងចែកឡើងវិញនូវសមត្ថកិច្ចរវាងក្រសួង ស្ថាប័នមានសមត្ថកិច្ចនៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្តល់សិទ្ធិ

អំណាច តួនាទី ភារកិច្ចឱ្យបានច្បាស់លាស់ និងធនធានសមស្របទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ការអភិវឌ្ឍ និងការអភិរក្សធនធានធម្មជាតិនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនប្រកបដោយការទទួលខុសត្រូវខ្ពស់។

- ផ្អែកតាមទស្សនៈវិស័យនៃការកែទម្រង់នេះ **គ.ជ.អ.ប** កំពុងធ្វើការសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីបែងចែកការទទួលខុសត្រូវ ដូចខាងក្រោម៖
  + **ក្រសួង ស្ថាប័ននៅថ្នាក់ជាតិ** ៖ មានតួនាទី ភារកិច្ច និងការទទួលខុសត្រូវទៅលើការរៀបចំគោលនយោបាយជាតិ ផែនការយុទ្ធសាស្ត្រជាតិ ផែនការប្រើប្រាស់ដីធ្លីជាតិ បទដ្ឋានបច្ចេកទេស អធិការកិច្ច ការអភិវឌ្ឍសមត្ថភាព និងការសម្រេចលើកិច្ចការសំខាន់ៗមួយចំនួនដូចជា ការកំណត់តំបន់ ប្រភេទ ព្រំប្រទល់ និងផែនទីព្រៃឈើ និងតំបន់គ្រប់គ្រងជលផល ការចុះបញ្ជិកាទ្រព្យសម្បត្តិធនធានធម្មជាតិ ការកំណត់កូតាប្រមូលផល និងកូតានាំចេញនាំចូល ការនាំចេញនាំចូលផល អនុផលព្រៃឈើ និងជលផលជាដើម។
  + **រដ្ឋបាលថ្នាក់ក្រោមជាតិ៖** មានតួនាទី និងការទទួលខុសត្រូវក្នុងការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រជាតិ និងបទដ្ឋានបច្ចេកទេសលើការគ្រប់គ្រង ការថែរក្សាការពារ ការអភិវឌ្ឍ និងការអភិរក្សធនធានធម្មជាតិដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
  + ជារួម ថ្នាក់ជាតិគឺជាអ្នកធ្វើគោលនយោបាយ ហើយរដ្ឋបាលថ្នាក់ក្រោមជាតិគឺជាអ្នកអនុវត្ត។ តែទោះជាយ៉ាងនេះក្តី ក្រសួង ស្ថាប័នមានសមត្ថកិច្ចនៅថ្នាក់ជាតិនៅតែជាស្ថាប័នដែលត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល និងរដ្ឋសភាក្នុងវិស័យព្រៃឈើ ជលផល និងតំបន់ការពារធម្មជាតិ។ ទន្ទឹមគ្នានេះ រដ្ឋបាលថ្នាក់ក្រោមជាតិគឺជាស្ថាប័នដែលត្រូវមានគណនេយ្យភាពចំពោះក្រសួង ស្ថាប័នមានសមត្ថកិច្ចនៅថ្នាក់ជាតិក្នុងការអនុវត្តតាមគោលនយោបាយជាតិ ផែនការយុទ្ធសាស្ត្រជាតិ និងបទដ្ឋានបច្ចេកទេសសម្រាប់ការគ្រប់គ្រង ការថែរក្សាការពារ ការអភិវឌ្ឍ និងការអភិរក្សធនធានធម្មជាតិដែលបានកំណត់ និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ និងសហគមន៍មូលដ្ឋានដែលជាអ្នកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនានា។
- ដើម្បីបែងចែកសមត្ថកិច្ចរវាងក្រសួង ស្ថាប័ននៅថ្នាក់ជាតិ រាជរដ្ឋាភិបាលក៏បានសម្រេចផ្ទេរសមត្ថកិច្ចគ្រប់គ្រងតំបន់ការពារ និងអភិរក្សព្រៃឈើទាំងអស់ទៅឱ្យស្ថិតក្រោមការគ្រប់គ្រង

របស់ក្រសួងបរិស្ថាន និងផ្ទេរសមត្ថកិច្ចគ្រប់គ្រងតំបន់វិនិយោគអភិវឌ្ឍន៍សម្បទានដីសេដ្ឋកិច្ចទាំងអស់ ទៅឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងបានដាក់បញ្ចូលតំបន់ព្រៃឈើមួយចំនួនបន្ថែមទៀតឱ្យក្លាយទៅជាតំបន់ការពារធម្មជាតិផងដែរ។

- ស្របពេលដែលមានការផ្ទេរសមត្ថកិច្ចគ្រប់គ្រងតំបន់ទាំងនេះ និងការរៀបចំធ្វើវិសោធនកម្មច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនានា បុគ្គលមួយចំនួនក៏បាន និងកំពុងឆ្លៀតឱកាសប្រព្រឹត្តបទល្មើសធនធានធម្មជាតិដ៏គួរឱ្យព្រួយបារម្ភ ជាពិសេសនៅក្នុងតំបន់ការពារធម្មជាតិនានា។

## III. ទិសដៅការងារបន្ត

- ដើម្បីធានាបានប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានធម្មជាតិនៅក្នុងដំណាក់កាលចំពោះមុខនេះ ក្នុងពេលដែលយើងកំពុងសិក្សាធ្វើវិសោធនកម្មច្បាប់ទាំង៣ សំដៅរៀបចំឡើងវិញនូវប្រព័ន្ធ និងរចនាសម្ព័ន្ធគ្រប់គ្រងព្រៃឈើ ជលផល និងតំបន់ការពារ រាជរដ្ឋាភិបាលបានដាក់ចេញនូវសារាចរណែនាំដោយផ្តោតលើវិធានការចាំបាច់ចំនួន **៩ចំណុច** ដូចតទៅ៖

   ១. អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តាមរយៈគណៈបញ្ជាការឯកភាពនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវដឹកនាំ សម្របសម្រួលកម្លាំងអធិការ ខណ្ឌ ផ្នែក សង្កាត់រដ្ឋបាលព្រៃឈើ អធិការ ខណ្ឌ ផ្នែក សង្កាត់រដ្ឋបាលជលផល មន្ទីរបរិស្ថាន និងកងកម្លាំងមានសមត្ថកិច្ចនានាដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យអនុវត្តឱ្យបានត្រឹមត្រូវនូវតួនាទីភារកិច្ចរបស់ខ្លួន សំដៅពង្រឹងសមត្ថកិច្ច និងការទទួលខុសត្រូវរបស់គណៈបញ្ជាការឯកភាពគ្រប់ថ្នាក់ចំពោះរាជរដ្ឋាភិបាលក្នុងការគ្រប់គ្រង ការថែរក្សា និងការការពារធនធានធម្មជាតិ ដោយត្រូវចាត់វិធានការឱ្យបានហ្មត់ចត់ក្នុងការទប់ស្កាត់ ការបង្ក្រាប និងការលុបបំបាត់បទល្មើសធនធានធម្មជាតិគ្រប់ប្រភេទ រួមទាំងការរុករានដីនៅក្នុងតំបន់ការពារ និងអភិរក្សធម្មជាតិដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

   - តាមរយៈវិធានការនេះ រៀងរាល់កិច្ចប្រជុំគណៈបញ្ជាការឯកភាពនៅថ្នាក់រាជធានី ខេត្តក្រុង ស្រុក ខណ្ឌ ត្រូវមានរបៀបវារៈពាក់ព័ន្ធការគ្រប់គ្រងព្រៃឈើ ជលផល និងតំបន់ការពារនានាដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

   - ក្នុងករណីដែលតំបន់ការពារមានការពាក់ព័ន្ធខេត្តច្រើន ត្រូវមានកិច្ចសហការរួមគ្នារវាងគណៈបញ្ជាការឯកភាពខេត្តដែលពាក់ព័ន្ធ។

- ហេតុនេះ ចាប់ពីពេលនេះខេត្ត ក្រុង ស្រុកណាដែលមានការកាប់បំផ្លាញព្រៃឈើ បទល្មើសព្រៃឈើ បទល្មើសនេសាទ និងបំផ្លិចបំផ្លាញធនធានធម្មជាតិ អភិបាលខេត្ត ក្រុង ស្រុកនោះ ត្រូវមានការទទួលខុសត្រូវចំពោះរាជរដ្ឋាភិបាល។

២. អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបង្កលទ្ធភាព និងលើកទឹកចិត្តឱ្យសហគមន៍មូលដ្ឋាន អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានាចូលរួមទប់ស្កាត់ និងលុបបំបាត់បទល្មើសធនធានធម្មជាតិគ្រប់ប្រភេទនៅក្នុងតំបន់ការពារ និងអភិរក្សធម្មជាតិដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នីមួយៗត្រូវរៀបចំកិច្ចប្រជុំជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ តំណាងអង្គការសង្គមស៊ីវិល អង្គការសហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធនានាឱ្យបានយ៉ាងតិចម្តងក្នុងមួយត្រីមាស ឬអាចកោះប្រជុំតាមការចាំបាច់ ដើម្បីពិនិត្យពិភាក្សាអំពីស្ថានភាពនៃការគ្រប់គ្រងធនធានធម្មជាតិ និងដើម្បីចាត់វិធានការជាក់ស្តែងនានាក្នុងការគ្រប់គ្រងធនធានធម្មជាតិនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាព។

- តាមរយៈវិធានការនេះ ត្រូវជំរុញ និងលើកទឹកចិត្តឲ្យមានកិច្ចសហការ និងការចូលរួមពីដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល ក្នុងការគ្រប់គ្រងធនធានធម្មជាតិជាអាទិ៍៖
  + ការរួមសហការគ្នាក្នុងការបង្ការ ទប់ស្កាត់ការកាប់បំផ្លាញព្រៃឈើ បទល្មើសជលផល និងការបំផ្លិចបំផ្លាញធនធានធម្មជាតិក្នុងតំបន់ការពារនានា។
  + ការសហការរួមគ្នាក្នុងការផ្សព្វផ្សាយអប់រំដល់ប្រជាពលរដ្ឋឲ្យចូលរួមថែរក្សាការពារធនធានធម្មជាតិ។
  + ការសហការរួមគ្នាក្នុងការរៀបចំចងក្រង បង្កើត និងពង្រឹងសហគមន៍ព្រៃឈើ សហគមន៍នេសាទ និងសហគមន៍នានាក្នុងតំបន់ការពារ ដើម្បីចូលរួមរក្សាការពារ និងអភិរក្សធនធានធម្មជាតិ។
  + ការសហការរួមគ្នាដើម្បីសិក្សាបង្កើតមុខរបរ បង្កើនប្រាក់ចំណូលសម្រាប់សហគមន៍ប្រជាពលរដ្ឋដែលរស់នៅក្បែរ ឬរស់នៅក្នុងតំបន់ការពារ ឬតំបន់ព្រៃឈើ នេសាទ ដើម្បីកាត់បន្ថយការពឹងអាស្រ័យផលមួយមុខតែទៅលើការកាប់ឈើ រួមនឹងការសិក្សាដើម្បីបង្កើនប្រាក់ចំណូល តាមរយៈការប្រមូលផលអនុផលព្រៃឈើ ប្រកបដោយនិរន្តរភាព។

- តាមរយៈវិធានការនេះ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមជំរុញលើកទឹកចិត្តដល់ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធទាំងអស់ មេត្តាផ្សារភ្ជាប់គម្រោង កម្មវិធី

នានារបស់ខ្លួនជាមួយក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល និងអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ ដើម្បីរួមគ្នាសម្រេចគោលដៅ គោលបំណងរួមដូចគ្នា នោះគឺការគ្រប់គ្រងអភិរក្សធនធានធម្មជាតិនៅកម្ពុជាប្រកបដោយនិរន្តរភាពរយៈពេលវែង។

៣. ប្រគល់សមត្ថកិច្ចដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីចាត់វិធានការឱ្យបានម៉ឺងម៉ាត់ និងហ្មត់ចត់ ដូចខាងក្រោម៖

- គ្រប់គ្រងរាល់សិប្បកម្មកែច្នៃ និងអាជីវកម្មធនធានព្រៃឈើ និងផលផលដែលមានច្បាប់អនុញ្ញាត ព្រមទាំងទប់ស្កាត់ និងលុបបំបាត់សិប្បកម្មកែច្នៃ និងអាជីវកម្មធនធានព្រៃឈើ និងផលផលដែលគ្មានច្បាប់អនុញ្ញាត។
- ត្រួតពិនិត្យ និងចាត់វិធានការលុបបំបាត់ការដឹកជញ្ជូន និងការស្តុកឈើគ្រប់ប្រភេទដែលគ្មានការអនុញ្ញាតត្រឹមត្រូវតាមច្បាប់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ វិធានការខាងលើនេះ ត្រូវសំដៅតែទៅលើការធ្វើអាជីវកម្មដែលខុសច្បាប់ ក្នុងនោះរួមទាំងការលួចបង្កើតកន្លែងសិប្បកម្មកែច្នៃឈើក្នុងតំបន់ការពារដែលមានខ្សែបណ្តាញផ្គត់ផ្គង់ឲ្យកន្លែងលក់ឈើ ឬរោងសិប្បកម្មនានា។ ទោះបីយ៉ាងណាក្តីការអនុវត្តវិធានការនេះមិនត្រូវធ្វើឲ្យប៉ះពាល់ដល់ការប្រើប្រាស់ឈើជាលក្ខណៈប្រពៃណីរបស់ប្រជាជននោះឡើយ ដូចជាការសាងសង់ផ្ទះសម្បែងជាដើម។
- ចាត់វិធានការទប់ស្កាត់ និងលុបបំបាត់ការនាំចេញឈើ និងផលិតផលកែច្នៃពីឈើគ្រប់ប្រភេទ ព្រមទាំងសត្វព្រៃដែលគ្មានការអនុញ្ញាតត្រឹមត្រូវតាមច្បាប់ ទៅក្រៅប្រទេសតាមច្រកទ្វារព្រំដែន និងតាមច្រករបៀង។
- គណៈបញ្ជាការឯកភាពខេត្ត ក្រុង ស្រុក ត្រូវដឹកនាំ សម្របសម្រួលអធិការ ខណ្ឌ ផ្នែក សង្កាត់រដ្ឋបាលព្រៃឈើ អធិការ ខណ្ឌ ផ្នែក សង្កាត់រដ្ឋបាលជលផល មន្ទីរបរិស្ថាន និងកម្លាំងមានសមត្ថកិច្ចពាក់ព័ន្ធទាំងឡាយ ដើម្បីធានាបាននូវការប្រើប្រាស់កម្លាំងសរុប និងមធ្យោបាយចាំបាច់នានាក្នុងការថែរក្សា និងការពារធនធានធម្មជាតិ ព្រមទាំងទប់ស្កាត់ និងបង្ក្រាបសកម្មភាពបទល្មើសនៅក្នុងតំបន់ការពារ និងអភិរក្សធម្មជាតិក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
- ខាងលើនេះជាវិធានការចំពោះមុខក្នុងពេលដែលយើងកំពុងសិក្សាធ្វើវិសោធនកម្មច្បាប់។ ការដឹកនាំកម្លាំងមានសមត្ថកិច្ចទាំងនេះត្រូវនៅក្រោមឆ័ត្រនៃគណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ ដើម្បីឲ្យមានការឯកភាពគ្នាអំពីវិធានការ និងកិច្ចសហប្រតិបត្តិការបង្ការ ទប់ស្កាត់ បង្ក្រាបបទល្មើសដ៏សាំញ៉ាំនេះ។

- ធ្វើរបាយការណ៍បូកសរុបប្រចាំត្រីមាស ឬធ្វើរបាយការណ៍ក្នុងករណីចាំបាច់ អំពីស្ថានភាពនៃការគ្រប់គ្រងតំបន់ការពារ និងអភិរក្សធម្មជាតិនានាដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនជូនក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយត្រូវចម្លងជូនក្រសួងមហាផ្ទៃ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស។ ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវធ្វើការបូកសរុបរបាយការណ៍ទាំងនេះ ដើម្បីរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល។

៤. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានរដ្ឋបាលព្រៃឈើជាសេនាធិការ ត្រូវត្រួតពិនិត្យ និងពង្រឹងការគ្រប់គ្រងឱ្យបានម៉ឺងម៉ាត់នូវការចេញលិខិតអនុញ្ញាតដឹកជញ្ជូនផល និងអនុផលព្រៃឈើគ្រប់ប្រភេទ ដើម្បីទប់ស្កាត់ និងលុបបំបាត់ការដឹកជញ្ជូនផល និងអនុផលព្រៃឈើខុសច្បាប់។

៥. ក្រសួងបរិស្ថាន ដោយមានអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិជាសេនាធិការត្រូវពង្រឹងយន្តការ និងផ្តល់កម្លាំងគាំទ្រដល់គណៈបញ្ជាការឯកភាពនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

៦. រាល់អន្តរាគមន៍របស់អង្គភាព ឬបុគ្គលដែលគ្មានសមត្ថកិច្ចលើការដឹកជញ្ជូនផល និងអនុផលព្រៃឈើ ត្រូវបានហាមឃាត់ជាដាច់ខាត ហើយនឹងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។

៧. ក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធត្រូវផ្តល់កិច្ចសហការ និងគាំទ្រដល់គណៈបញ្ជាការឯកភាពនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌក្នុងការអនុវត្តវិធានការទាំងនេះ។

សរុបមក វិធានការក្នុងសារាចរណែនាំនេះ បានប្រគល់ការទទួលខុសត្រូវភាគច្រើនទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងគណៈបញ្ជាការឯកភាពរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ វិធានការនេះ មិនបានសេចក្តីថាក្រសួង ស្ថាប័នថ្នាក់ជាតិទំលាក់ការទទួលខុសត្រូវទាំងអស់ទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិនោះឡើយ។ ដូចដែលបានបញ្ជាក់ពីខាងលើរួចហើយ គឺក្រសួង ស្ថាប័នមានសមត្ថកិច្ចនៅថ្នាក់ជាតិ នៅតែមានការទទួលខុសត្រូវចំពោះមុខរាជរដ្ឋាភិបាល និងរដ្ឋសភា អំពីការគ្រប់គ្រង និងអភិរក្សធនធានព្រៃឈើ ជលផល និងតំបន់ការពារនានា។

វិធានការនេះមានគោលបំណងលើកកម្ពស់កិច្ចសហការ ការគាំទ្រ និងការទទួលខុសត្រូវរួមគ្នារវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមទាំងអ្នកពាក់ព័ន្ធនានា។

៨. ក្នុងករណីចាំបាច់ គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត អាចស្នើសុំកម្លាំងអន្តរាគមន៍ជាបន្ទាន់មកមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

៩. រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវដឹកនាំកិច្ចប្រជុំត្រួតពិនិត្យការងារគ្រប់គ្រងធនធនធម្មជាតិរៀងរាល់ត្រីមាស ឬអាចកោះប្រជុំតាមការចាំបាច់។

## IV. កិច្ចការបន្ទាន់បន្ទាប់ពីកិច្ចប្រជុំនេះ

- បន្ទាប់ពីកិច្ចប្រជុំផ្សព្វផ្សាយនេះ ដើម្បីធានាដល់ការអនុវត្តសារាចរណែនាំនេះឱ្យមានប្រសិទ្ធភាព ខ្ញុំសូមផ្តល់គោលការណ៍ណែនាំមួយចំនួនដូចខាងក្រោម៖

**ទីមួយ៖** ក្រសួង ស្ថាប័ន និងអង្គភាពមានសមត្ថកិច្ចទាំងអស់ត្រូវរៀបចំផ្សព្វផ្សាយខ្លឹមសារសារាចរណែនាំនេះ ភ្ជាប់ជាមួយវិធានការអនុវត្តជាក់ស្តែងដល់មន្ត្រីក្រោមឱវាទ និងត្រូវចាត់ចែងឱ្យមានមន្ត្រីជំនាញទទួលបន្ទុកច្បាស់លាស់ ព្រមទាំងត្រូវរៀបចំឱ្យមានកញ្ចប់ថវិកា មធ្យោបាយ ឧបករណ៍ និងសម្ភារ បរិក្ខារចាំបាច់នានាសម្រាប់ការអនុវត្តវិធានការតាមសមត្ថកិច្ចរបស់ខ្លួន ដូចដែលបានកំណត់ក្នុងសារាចរណែនាំនេះឱ្យមានប្រសិទ្ធភាព និងត្រូវធ្វើការតាមដាន ត្រួតពិនិត្យការអនុវត្ត ព្រមទាំងការធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាលឲ្យបានទៀងទាត់។

**ទីពីរ៖** - អភិបាលរាជធានី ខេត្តក្នុងនាមជាប្រធានគណៈបញ្ជាការឯកភាព ត្រូវដឹកនាំផ្សព្វផ្សាយសារាចរណែនាំនេះឱ្យបានទូលំទូលាយជូនដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ សហគមន៍មូលដ្ឋាន អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា និងត្រូវសហការគ្នារៀបចំផែនការសកម្មភាពឱ្យបានជាក់លាក់ ព្រមទាំងត្រូវខិតខំកៀរគរការគាំទ្រ និងការចូលរួមចំណែកពីសហគមន៍មូលដ្ឋាន អង្គការសង្គមស៊ីវិលក្នុងការអនុវត្តវិធានការនានា ដូចបានកំណត់ក្នុងសារាចរណែនាំនេះ ផ្អែកតាមស្ថានភាពជាក់ស្តែងនៅតាមមូលដ្ឋាននីមួយៗ។

- កិច្ចសហការគ្នាបានល្អរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយសហគន៍មូលដ្ឋាន និងអង្គការសង្គមស៊ីវិល គឺជាកត្តាដ៏សំខាន់ក្នុងការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិ តួយ៉ាងក្នុងរូបភាពជាសហគមន៍ព្រៃឈើជាដើម។ បច្ចុប្បន្ននេះ យើងកំពុងទទួលបាននូវ

ការសាទរ និងការគាំទ្រពីសហគមន៍មូលដ្ឋាន អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានាទៅលើកំណែទម្រង់ការគ្រប់គ្រងធនធានធម្មជាតិនេះ។ ជាក់ស្តែង ដៃគូអភិវឌ្ឍន៍របស់យើង មានជាអាទិ៍ដូចជាគម្រោងគាំទ្រព្រៃឈើ និងជីវចម្រុះដែលគាំទ្រដោយ USAID បានបង្ហាញឆន្ទៈ និងត្រៀមខ្លួនជាស្រេចក្នុងការជួយគាំទ្រដល់ខេត្តទាំង៤ក្នុងតំបន់ព្រៃឡង់គឺ ខេត្តកំពង់ធំ ព្រះវិហារ ស្ទឹងត្រែង និងខេត្តក្រចេះ ក្នុងការចាត់វិធានការនានាដើម្បីអនុវត្តសារាចរណែនាំនេះ។ ក្នុងន័យនេះ ខ្ញុំសូមជំរុញ និងលើកទឹកចិត្តដល់រដ្ឋបាលខេត្តទាំងនេះ និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់បង្កើនកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ សហគមន៍មូលដ្ឋាន អង្គការសង្គមស៊ីវិលនានាលើកិច្ចការដ៏មានសារៈសំខាន់នេះ។ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវចាត់ទុកកិច្ចការនេះជាអាទិភាពដ៏សំខាន់មួយ ហើយខ្ញុំនឹងរង់ចាំទទួលនូវរបាយការណ៍ និងតាមដានការអនុវត្តសារាចរណែនាំនេះជាប្រចាំ។

**ទីបី៖** ស្នើឲ្យក្រសួង ស្ថាប័នពាក់ព័ន្ធបន្តផ្តល់ការណែនាំឲ្យបានច្បាស់លាស់ដល់មន្ទីរ អង្គភាពក្រោមឱវាទរបស់ខ្លួននៅមូលដ្ឋានក្នុងការផ្តល់កិច្ចសហការ និងគាំទ្រដល់គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងការទប់ស្កាត់ការកាប់រាន ការដុត ការឈូសឆាយ និងការហ៊ុមព័ទ្ធកាន់កាប់ដីព្រៃឈើធ្វើជាកម្មសិទ្ធិដោយខុសច្បាប់ ព្រមទាំងទប់ស្កាត់ការកាប់បំផ្លាញព្រៃឈើ។

**ទីបួន៖** មេបញ្ជាការកងយោធពលខេមរភូមិន្ទ មេបញ្ជាការកងនគរបាលការពារព្រំដែន ដែលឈរជើងនៅតាមបណ្តោយព្រំដែនកម្ពុជាជាមួយប្រទេសជិតខាង និងសមត្ថកិច្ចជំនាញប្រចាំនៅច្រកទ្វារព្រំដែន ត្រូវចាត់វិធានការឲ្យបានម៉ឺងម៉ាត់បំផុត ដើម្បីទប់ស្កាត់ការនាំឈើចេញដោយខុសច្បាប់នៅតាមច្រកទ្វារព្រំដែន និងច្រករបៀង។ ករណីមានការនាំឈើចេញក្នុងភូមិសាស្ត្រឈរជើងរបស់អង្គភាពណាមួយ ឬច្រកទ្វារណាមួយ អង្គភាពនោះត្រូវទទួលខុសត្រូវចំពោះមុខរាជរដ្ឋាភិបាល។

យើងតែទទួលបានព័ត៌មាន ឬរបាយការណ៍ជាបន្តបន្ទាប់អំពីការនាំចេញឈើខុសច្បាប់តាមច្រកព្រំដែន និងច្រករបៀងនានា។ ករណីនេះ ចាប់ពីពេលនេះ គណៈបញ្ជាការឯកភាពខេត្ត កម្លាំងឈរជើងតាមព្រំដែន ប្រធានប៉ុស្តិ៍ ប្រធានច្រក ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ករណីមានបទល្មើសកើតឡើង។ មេបញ្ជាការកងរាជអាវុធហត្ថ អគ្គស្នងការនគរបាលជាតិ និងអភិបាលខេត្តត្រូវស្រាវជ្រាវជាបន្ទាន់ ករណីមានព័ត៌មាន ឬមានរបាយការណ៍អំពីការនាំចេញដោយខុសច្បាប់នូវឈើ ផល អនុផលព្រៃឈើ សត្វព្រៃ តាមច្រកព្រំដែន ឬតាមច្រករបៀងនានា។

**ទីប្រាំ៖** ដូចខ្ញុំបានគូសបញ្ជាក់ពីខាងដើម ការដាក់ចេញនូវសារាចរណែនាំនេះ គឺជាវិធានការសម្រាប់ដោះស្រាយបញ្ហាបន្ទាន់ចំពោះមុខៗ ដើម្បីជានាដល់ការពង្រឹងការគ្រប់គ្រង ការអភិវឌ្ឍ និងការអភិរក្សធនធានធម្មជាតិប្រកបដោយនិរន្តរភាពសម្រាប់រយៈពេលវែង យើងត្រូវធ្វើវិសោធនកម្មច្បាប់ និងលិខិតដ្ឋានគតិយុត្តពាក់ព័ន្ធនានា។ ក្នុងន័យនេះ ខ្ញុំសូមស្នើឱ្យលេខាធិការដ្ឋាន **គ.ជ.អ.ប** និងក្រសួងមហាផ្ទៃត្រូវបន្តសហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន ក្នុងការរៀបចំសេចក្តីព្រាងវិសោធនកម្មច្បាប់ទាំង៣ គឺច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល និងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ដើម្បីដាក់ឱ្យមានការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធនានា មុននឹងដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេចតាមនីតិវិធីជាធរមាន។

- ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធិពរជូនឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈកុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ!**